THE SCHOOL DISTRICT OF PHILADELPHIA
OFFICE OF STUDENT SUPPORT SERVICES

**OFFICE OF STUDENT SUPPORT SERVICES**
Suite 210
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០២២

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

នៅពេលដែលសិស្សានុសិស្ស និងបុគ្គលិកស្ថិតនៅក្នុងភាពរួចរាល់សម្រាប់ឆ្នាំសិក្សាថ្មី យើងចង់ចែករំលែកព័ត៌មានថ្មីៗអំពីសុខភាព និងសុវត្ថិភាព និងការរំលឹកមួយចំនួន ជាមួយលោកអ្នក។

យើងបានកែសម្រួល ពិធីការទូទៅសម្រាប់ COVID-19 សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣ របស់យើង ដើម្បីផ្តល់ភាពច្បាស់លាស់បន្ថែមចំពោះពិធីការដែលយើងបានបញ្ចេញកាលពីដើមខែសីហា។ លោកអ្នកអាចពិនិត្យមើលពិធីការទាំងមូល ហើយមើលការកែប្រែដែលបានរាយក្នុងបញ្ជីយ៉ាងច្បាស់ នៅខាងលើ ដែលនៅ ត្រង់នេះ។

ចាប់ផ្តើមនៅសប្តាហ៍ក្រោយ ការពាក់ម៉ាស់នឹងធ្វើទៅតាមជម្រើស ប៉ុន្តែត្រូវបានគេស្នើសុំឱ្យពាក់។ ដូចបានរៀបរាប់នៅក្នុងពិធីការ ក្រសួងអប់រំ**អាច**តម្រូវឱ្យពាក់ម៉ាស់ឡើងវិញជាបណ្តោះអាសន្ន ក្នុងកាលៈទេសៈអ្វីមួយ រួមទាំងពេលដែល COVID-19 នៅក្នុងសហគមន៍មានកម្រិតខ្ពស់ យោងទៅលើ ការចង្អុលបង្ហាញកម្រិត COVID-19 នៅក្នុងសហគមន៍ ដោយមជ្ឈមណ្ឌលការពារជម្ងឺ។ យើងទទួលស្គាល់ថា ក្មេងខ្លះមានលក្ខណៈដែលអាចរារាំងពួកគេពីការពាក់ម៉ាស់ដោយសុវត្ថិភាព ឬមានប្រសិទ្ធភាព។ នៅក្នុងករណីទាំងនេះ ឪពុកម្តាយ ឬអាណាព្យាបាលអាចបំពេញលិខិតស្នើសុំ ការជួយសម្រួលទៅតាមសេចក្តីត្រូវការ ដែលអាចឃើញមាននៅលើ គេហទំព័រអំពីពិធីការសុខភាណ និងសុវត្ថិភាព។

ដើម្បីគាំទ្រដល់បរិស្ថានសាលាឱ្យមានសុខភាពល្អថែមទៀត គេបានសុំឱ្យ មាតាបិតា និងអាណាព្យាបាល ធ្វើការណាត់ជួបសម្រាប់ការចាក់ថ្នាំបង្ការ COVID-19 **និង**ជំងឺគ្រុនផ្តាសាយ។ ក្មេងដែលគ្រប់អាយុចូលរៀនទាំងអស់មានសិទ្ធិទទួលការចាក់ថ្នាំទាំងនេះ ដែលថ្នាំទាំងពីរនេះបានបង្ហាញថាមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្ការជំងឺ ហើយអាចចាក់ឱ្យដោយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក ឬនៅឱសថស្ថានក្នុងតំបន់។

ជាចុងក្រោយ ក្រសួងអប់រំនៅតែបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងសាធារណៈសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដើម្បីតាមដានករណីជំងឺ អុតធំម្យ៉ាង (Monkeypox) នៅទីក្រុង ហ្វីឡាដែលហ្វ្យ៉ា។ ផ្អែកលើទិន្នន័យបច្ចុប្បន្ន ហានិភ័យនៃការឆ្លងរោគទាំងពីរនេះក្នុងចំណោមក្មេងៗ និងការឆ្លងរាលដាលនៅសាលាគឺមានកម្រិតទាបណាស់។ សូមមើល គេហទំព័រអំពីពិធីការសុខភាណ និងសុវត្ថិភាព ដើម្បីស្វែងរកព័ត៌មានអំពី Monkeypox

សម្រាប់ក្រុមគ្រួសារ ជាឯកសារដែលផ្តល់ការពិពណ៌នាទូទៅអំពី Monkeypox របៀបមើលឱ្យដឹងពីជម្ងឺនេះ និងអ្វីដែលត្រូវធ្វើប្រសិនបើកូនរបស់លោកអ្នកមានរោគសញ្ញា ឬធ្វើតេស្តវិជ្ជមាន។

ក្រសួងអប់រំមានការប្តេជ្ញាក្នុងការផ្តល់ដំណឹងថ្មីៗ ឬការផ្លាស់ប្តូរលក្ខណៈសុខភាពសាធារណៈនៅសាលារបស់យើង។ លោកអ្នកអាចស្វែងរកព័ត៌មានថ្មីៗដោយមើល មជ្ឈមណ្ឌលផ្ទុកព័ត៌មានអំពី Covid-19 ឬ គេហទំព័រអំពីពិធីការសុខភាព និងសុវត្ថិភាព។

ដោយសេចក្តីស្មោះស្ម័គ្រ

*Dr. Kendra McDow*

Dr. Kendra B. McDow
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
មន្ត្រីពេទ្យក្រសួងអប់រំ